ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ.០៣៦.....ប្រក.កសក

ប្រកាស
ស្តីពី
ការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តមណ្ឌលគិរី

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- *បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រមលេខ ០២/នស/៩៦ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ*
- *បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*
- *បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*
- *បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ*
- *បានឃើញប្រកាសលេខ២៦៩ប្រក.កសក ចុះថ្ងៃទី៦១ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ*
- *តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ*

សម្រេច

ប្រការ ១.-

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តមណ្ឌលគិរី សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាព តាមលក្ខណៈសហគមន៍ព្រៃឈើ ដែលមានទីតាំងស្ថិតនៅក្នុងផ្នែករដ្ឋបាលព្រៃឈើសែនមនោរម្យនៃខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី។

ប្រការ ២.-

ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលបំណង ៖

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវចម្រុះ និងអភិវឌ្ឍព្រៃសហគមន៍ឲ្យមាននិរន្តរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីសម្រាប់ការរស់នៅ ទំនៀមទម្លាប់និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមលទ្ធភាពធនធាន និងសក្តានុពលព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

ប្រការ ៣.-

តំបន់ព្រៃសហគមន៍ក្នុងខេត្តមណ្ឌលគិរីនៃប្រកាសនេះមានបួន(៤)សហគមន៍ព្រៃឈើចែកចេញបួនកន្លែងដែលមានផ្ទៃដីសរុបចំនួន ៤១៧៦(បួនពាន់មួយរយចិតសិបប្រាំមួយ)ហិកតាដូចមានក្នុងផែនទីភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះនិងជាប្រព័ន្ធខ្សែព្រំបិទជិតកំណត់ដោយចំណុចគោលនិងនិយាមកាដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ។ ក្នុងករណីមានការចាំបាច់ព្រំប្រទល់ព្រៃសហគមន៍ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះអាចកែសម្រួលបានតាមការជាក់ស្តែង។

ប្រការ ៤.-

ដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះ ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។

ប្រការ ៥.-

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ៦.-

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាន នីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្មខេត្តមណ្ឌលគិរី ត្រូវអនុវត្តប្រកាសនេះតាមការកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៣

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងការពារជាតិ*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*
- *ក្រសួងបរិស្ថាន*
- *សាលាខេត្តមណ្ឌលគិរី*
- *ដូចប្រការ ៦*
- *ឯកសារ កាលប្បវត្តិ*

ឧបសម្ព័ន្ធ ១ ៖ ភ្ជាប់ប្រកាសលេខ ...ប.ស.ប/ប្រ/...ប្រកាស... ចុះថ្ងៃទី ...១៥... ខែ ...កុម្ភៈ... ឆ្នាំ ...២០១៣

ផែនទី ទីតាំងព្រៃសហគមន៍ក្នុងខេត្តមណ្ឌលគិរី



ខេត្តមណ្ឌលគិរី ថ្ងៃទី ...១៦... ខែ ...ធ្នូ... ឆ្នាំ ...២០១២...

ឧបសម្ព័ន្ធ ២ ៖ភ្ជាប់ប្រកាសលេខ ..១៣៧..ប្រក.កសក ចុះថ្ងៃទី ..១៩.....ខែ ....តុលា.....ឆ្នាំ.....ឆ្នាំ២០១៣..

ទីតាំងព្រៃសហគមន៍ក្នុងខេត្តមណ្ឌលគិរី

លរ	ឈ្មោះសហគមន៍ព្រៃឈើ	ផ្ទៃដី (ហិកតា)	ចំណុចនិយាមការ ទីតាំងព្រៃសហគមន៍				ចំនួនភូមិ	ឈ្មោះឃុំ	ឈ្មោះស្រុក	ផ្នែករដ្ឋបាលព្រៃឈើ
១	ភូមិពូក្រូច	១២៣១	753018 -1385773	750586 -1384252	749589 -1383252	747652 -1385476	១	ស្រែអំពួម	ពេជ្រាដា	សៃនមនោរម្យ
			752109 -1385155	750125 -1384070	749011 -1383861	748592 -1385419				
			751706 -1384986	750089 -1383662	748245 -1384165	751330 -1388158				
			751301 -1384771	749881 -1383296	747367 -1385112					
២	ភូមិពូលូង	៩៤៤	744605 -1392516	747018 -1389490	744254 -1389907	744063 -1391336	១	រមនា	សៃនមនោរម្យ	សៃនមនោរម្យ
			744842 -1392186	746690 -1389520	744346 -1390067	743952 -1391674				
			745200 -1392000	746208 -1389083	744260 -1390480	743983 -1391921				
			747677 -1392000	746058 -1388793	744383 -1390862	744322 -1392214				
			747677 -1390149	744297 -1389606	744180 -1391157	744383 -1392563				
			747404 -1389882							
៣	ភូមិពូក្រវ៉ង	៦៧៨	757804 -1390924	756679 -1390829	758507 -1393989	757924 -1391610	១	ស្រែអំពួម	ពេជ្រាដា	សៃនមនោរម្យ
			757325 -1390969	756669 -1395291	758440 -1393615					
			757142 -1390873	757975 -1395019	758250 -1392832					
			756973 -1390894	758481 -1394441	758754 -1392423					
៤	ភូមិពូភ៉ាដែត	១៣៦៣	758984 -1389760	757695 -1385490	755910 -1387488	758379 -1388907	១	ស្រែអំពួម	ពេជ្រាដា	សៃនមនោរម្យ
			758984 -1387014	757270 -1385235	756101 -1387743	758239 -1388948				
			760927 -1387014	755145 -1385787	756314 -1388003					
			761181 -1385447	755378 -1386064	757335 -1388002					
			758312 -1385426	755719 -1386659	757335 -1388354					
			757993 -1385213	755655 -1386978	758325 -1388558					
សរុប		៦១៧៦					០៤	០៦	០៦	០១

ផែនទី បង្ហាញទីតាំងកន្លែងស្នាក់នៅ ស៊ីសង្វៀនក្នុងឃុំច្រែងជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី
ខេត្តមណ្ឌលគីរី
ស្រុកពេជ្រាដា
ច្រែងជ្រៃ
ច្រែងជ្រៃ
Coordinate Systems
Zone: 48P
Projection: UTM
Map Datum: Indian 1960
ទាក់ទង 1:35,000
0 500 1,000
Meters

ខេត្តមណ្ឌលគិរី
ក្រុងសែនមនោរម្យ
សញ្ញាសម្គាល់
ទីតាំងភូមិ
ប្រៃបាស់ស្រុក
ផ្លូវថ្នល់
ប្រៃបាស់ព្រៃសេចក្តីអន្តរាយព្រៃឈើ ២០០២
ព្រៃស្រោង
ព្រៃកោះកណ្តាលស្រោង
ព្រៃឈើ
ព្រៃដូង
ដីធ្លាតម្រៃប្រៃ
ទីតាំងគម្រោង
Geographic Systems
Zone 48P
Projection: UTM
Map Datum Indian 1960
ទាក់ទង 1:25,000
0 450 900
Meters

ខេត្តបន្ទាយមានជ័យ
ស្រុកចង្រ្កាវ
សញ្ញាសម្គាល់
ចំណុចមិនយោគ
ផ្លូវ
ព្រំប្រទល់ស្រុកនិងឃុំ
ព្រំប្រទល់ខេត្តនិងស្រុក
ដីស្ថិតក្នុងព្រំប្រទល់
ព្រៃស្រោង
ព្រៃកក់ណូលស្រោង
ព្រៃឈើ
ព្រៃស្មៅ
ដីស្ថិតក្នុងព្រំប្រទល់
Coordinate Systems
Zone: 48P
Projection: UTM
Map Datum: Indian 1960
ទម្រង់ផែន 1:29,000
0 500 1,000
Meters


ផែនទី ព្រៃសហគមន៍តូមិញរ៉ាជែត ស្ថិតនៅក្នុងឃុំស្រែអំពុម ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី
755000
756000
757000
758000
759000
760000
761000
1390000
1389000
1388000
1387000
1386000
1385000
ឃុំប្ញស្រា
ឃុំពាមជរ
ឃុំពាមជរ
ឃុំប្ញស្រា
ឃុំពាមជរ
ឃុំប្ញស្រា
ឃុំពាមជរ
ឃុំប្ញស្រា